# បរិយាយប័ណ្ណឱសថ
# ហ្វែរ៉ូស្ពីយ៍ ចាក់តាមសរសៃឈាម

# FERROSPEY

## Elemental Iron 100mg

I **រូបភាពឱសថ** :
-ជាឱសថប្រភេទទឹកសំរាប់ចាក់តាមសរសៃឈាម
-១ប្រអប់មាន ៥អំពូល ១អំពូលមានចំណុះ 5ml

II **សមាសធាតុផ្សំ** : ក្នុង 5ml មាន៖
-Elemental Iron.......................... 100mg

III **គុណភាពព្យាបាល** :
ឱសថនេះប្រើសំរាប់ព្យាបាលជំងឺខ្វះជាតិដែក ដូចខាងក្រោម៖
-សំរាប់ជំងឺដែលត្រូវការការចែកចាយជាតិដែកឆាប់រហ័សទៅកាន់កន្លែងស្តុកទុកជាតិដែកក្នុងខ្លួន។
-សំរាប់អ្នកជំងឺដែលមិនអាចលេបថ្នាំគ្រាប់ជាតិដែកតាមមាត់បាន។
-សំរាប់អ្នកមានជំងឺរលាកពោះវៀនស្រួចស្រាវ ហើយដែលការប្រើថ្នាំជាតិដែកលេបតាមមាត់មិនមាន ប្រសិទ្ធភាព។

IV **ការហាមប្រើ** :
ឱសថនេះហាមប្រើចំពោះល័ក្ខខ័ណ្ឌដូចខាងក្រោម៖
-អ្នកងាយមានប្រតិកម្មជាមួយនឹងសារធាតុផ្សំណាមួយនៃឱសថនេះ
-អ្នកមានជំងឺស្លេកស្លាំងដែលមិនទាក់ទងជាមួយនឹងបញ្ហាកង្វះជាតិដែក
-អ្នកមានជំងឺលើសកំរិតជាតិដែកក្នុងខ្លួន ឬមានវិបត្តិការប្រើប្រាស់ជាតិដែកក្នុងខ្លួន

V **ការប្រុងប្រយ័ត្ន** :
ឱសថនេះត្រូវមានការប្រុងប្រយ័ត្នចំពោះល័ក្ខខ័ណ្ឌដូចខាងក្រោម:
-ចំពោះអ្នកមានជំងឺហឺត ជំងឺរើម ជំងឺអាល្លែកហ្ស៊ី
-ចំពោះអ្នកងាយមានប្រតិកម្មអាល្លែកហ្ស៊ីជាមួយសូលុយស្យុងជាតិដែកសំរាប់ចាក់ផ្សេងទៀត
-ចំពោះអ្នកមានជំងឺខ្សោយមុខងារថ្លើម
-ចំពោះអ្នកមានជំងឺឆ្លងស្រួចស្រាវ
-ចំពោះអ្នកមានជំងឺកង្វះអាស៊ីតហ្វូលិក ឬថយចុះកំរិតសេរ៉ូមជាតិដែកក្នុងឈាម
-សូលុយស្យុងជាតិដែកសំរាប់ចាក់ អាចបណ្តាលឲ្យមានប្រតិកម្មអាល្លែកហ្ស៊ី និងហ្សុកអាណាហ្វីឡាក់ទិកកើតឡើង។ ដូច្នេះ វិធានការសំរាប់បង្ការ ឬព្យាបាលប្រតិកម្មអាល្លែកហ្ស៊ីធ្ងន់ធ្ងរគឺត្រូវត្រៀមជាចាំបាច់។
-ត្រូវត្រួតពិនិត្យមើលកំរិតជាតិដែកក្នុងឈាមឲ្យបានទៀងទាត់ជាពិសេសពេលប្រើចំពោះអ្នកជំងឺខ្សោយមុខងារថ្លើម
-ត្រូវបញ្ឈប់ការប្រើឱសថនេះចំពោះអ្នកជំងឺដែលរកឃើញថាមានជំងឺបាក់តេរីក្នុងឈាម
-ការចាក់ថ្នាំនេះលឿនពេកអាចបណ្តាលឲ្យសំពាធឈាមថយចុះ
-ការប្រើថ្នាំនេះលើសកំរិតណែនាំអាចបណ្តាលឲ្យឈឺសន្លាក់
-ត្រូវជៀសវាងកុំឲ្យមានហូរថ្នាំចេញក្រៅសរសៃឈាមពេលចាក់ព្រោះវាអាចធ្វើឲ្យឈឺលើកន្លែងចាក់ រលាក ក្រិន ជាលិកាស្បែក និងស្បែកឡើងពណ៌ត្នោត
-ចំពោះស្ត្រីមានផ្ទៃពោះ៖ ឱសថនេះមិនណែនាំឲ្យប្រើចំពោះស្ត្រីមានផ្ទៃពោះក្នុងត្រីមាសទី១ តែអាចប្រើក្នុងត្រីមាសទី២និងទី៣កាលណាផលចំណេញមានច្រើនជាងហានិភ័យលើទារកក្នុងផ្ទៃ។
-ចំពោះស្ត្រីបំបៅដោះកូន៖ ត្រូវផ្អាក ឬបញ្ឈប់ការបំបៅដោះកូនអំឡុងពេលប្រើឱសថនេះ
-មិនត្រូវប្រើឱសថនេះលើសកំរិតណែនាំ
-មិនត្រូវប្រើឱសថនេះហួសកាលបរិច្ឆេទប្រើប្រាស់

VI **ផលរំខាន** :
-វិបត្តិប្រព័ន្ធសរសៃប្រសាទកណ្តាល៖ ភ្លាវភ្លាំងមាត់ ឈឺក្បាល ធេងធោង ឈឺផៀបៗចុងម្រាមដៃម្រាមជើង សន្លប់ មិនអាចផ្តោតអារម្មណ៍បានល្អ មានអារម្មណ៍ក្រហាយ
-វិបត្តិប្រព័ន្ធសរសៃឈាមបេះដូង៖ សំពាធឈាមថយចុះ បេះដូងដើរញាប់ ញ័រទ្រូង និងសំពាធឈាមកើនឡើង
-វិបត្តិប្រព័ន្ធផ្លូវដង្ហើម៖ កន្ត្រាក់ទងសួត ពិបាកដកដង្ហើម
-វិបត្តិក្រពះពោះវៀន៖ ចង្អោរ ក្អួត រាក ឈឺពោះ
-វិបត្តិស្បែកនិងជាលិកាស្បែក៖ កន្ទួលក្រហមស្បែក រមាស់ស្បែក កន្ទាលត្រអាក ហើមស្បែក
-វិបត្តិឆ្អឹងសាច់ដុំ៖ ឈឺសាច់ដុំ រមួលក្រពើ
-វិបត្តិប្រព័ន្ធស៊ាំសរីរាង្គ៖ ប្រតិកម្មអាណាហ្វីឡាក់ទិក (កំរកើតមាន)
-វិបត្តិទូទៅនិងនៅលើកន្លែងចាក់៖ ក្តៅខ្លួន ញ័រខ្លួន មុខឡើងក្រហម ឈឺទ្រូងនិងណែនទ្រូង អស់កម្លាំង និងវិបត្តិលើកន្លែងចាក់ដូចជា ឈឺលើកន្លែងចាក់ រលាកសរសៃឈាម ក្រហាយ ហើម

VII **អន្តរកម្មឱសថ** :
គួរជៀសវាងប្រើរួមគ្នាក្នុងពេលតែមួយជាមួយឱសថដូចខាងក្រោម៖
-ឱសថជាតិដែកសំរាប់ចាក់ផ្សេងទៀត។
-ឱសថនេះអាចប្រើលាយជាមួយសេរ៉ូមប្រៃ sodium chloride 0.9% តែប៉ុណ្ណោះ។

VIII **ការរក្សាទុក** :
-ត្រូវទុកនៅក្រោមសីតុណ្ហភាព ៣០°C
-ត្រូវទុកកុំឲ្យត្រូវកំដៅថ្ងៃ និងសំណើម
-ត្រូវទុកឲ្យផុតពីដៃកូនក្មេង។

IX **កំរិត និងរបៀបប្រើ** :

❖ **របៀបប្រើ៖**
-ឱសថនេះប្រើចាក់តាមសរសៃឈាមតែប៉ុណ្ណោះ។
-ឱសថនេះត្រូវចាក់យឺតៗតាមសរសៃឈាម ឬចាក់លាយជាមួយសេរ៉ូមប្រៃព្យួរតាមសរសៃឈាម។
-មុនពេលប្រើ កំរិតប្រើដំបូងចំពោះអ្នកជំងឺថ្មីម្នាក់ ត្រូវធ្វើតេស្តកំរិតប្រើនៃឱសថនេះសិន។
-មិនត្រូវប្រើឱសថនេះចាក់តាមសាច់ដុំទេ។
-មុនពេលបើកអំពូលថ្នាំ ត្រូវពិនិត្យមើលអំពូលថ្នាំ និងសូលុយស្យុងក្នុងអំពូលថ្នាំថាតើវាមានប្រេះស្រាំ ឬមានកករក្នុងអំពូលថ្នាំដែរឬទេ។

❖ **កំរិតប្រើ៖**

**សំរាប់ប្រើលាយជាមួយសេរ៉ូមព្យួរតាមសរសៃឈាម៖**
-ជាការល្អប្រសើរ ឱសថនេះត្រូវចាក់លាយជាមួយសេរ៉ូមព្យួរតាមសរសៃឈាម ដើម្បីបន្ថយសំពាធគ្រាប់ឈាមនិងជៀសវាងកុំឲ្យមានហូរសូលុយស្យុងថ្នាំក្រៅសរសៃឈាម។
-ភ្លាមៗ មុនពេលចាក់បញ្ចូលតាមសរសៃឈាម ត្រូវលាយឱសថនេះជាមួយសូលុយស្យុងសេរ៉ូមប្រៃ ០,៩%(sodium chloride 0.9%) ក្នុងសមាមាត្រ ១:២០, ឧទាហរណ៍ លាយ 1ml (20mg នៃជាតិដែក) ទៅក្នុង 20ml នៃសូលុយស្យុងសេរ៉ូមប្រៃ ០,៩%(sodium chloride 0.9%)។
ការលាយសូលុយស្យុងថ្នាំនេះត្រូវធ្វើភ្លាមៗមុនពេលព្យួរតាមសរសៃឈាម ហើយសូលុយស្យុងថ្នាំនេះត្រូវប្រើដូចខាងក្រោម៖

- 100mg នៃជាតិដែក (5ml នៃឱសថ Ferrospey) ត្រូវព្យួរក្នុងរយៈពេលយ៉ាងហោចណាស់១៥នាទី
- 200mg នៃជាតិដែក (10ml នៃឱសថ Ferrospey) ត្រូវព្យួរក្នុងរយៈពេលយ៉ាងហោចណាស់៣០នាទី
- 300mg នៃជាតិដែក (15ml នៃឱសថ Ferrospey) ត្រូវព្យួរក្នុងរយៈពេលយ៉ាងហោច១ម៉ោងនិង៣០នាទី
- 400mg នៃជាតិដែក ត្រូវព្យួរក្នុងរយៈពេលយ៉ាងហោចណាស់ ២ម៉ោងនិង៣០នាទី
- 500mg នៃជាតិដែក ត្រូវព្យួរក្នុងរយៈពេលយ៉ាងហោចណាស់ ៣ម៉ោងនិង៣០នាទី
- ការចាប់ផ្តើមប្រើកំរិតអតិបរិមា 7mg នៃជាតិដែក ក្នុងទម្ងន់ខ្លួន១គីឡូក្រាម ត្រូវធ្វើឡើងដោយការព្យួរសេរ៉ូមក្នុងរយៈពេលយ៉ាងហោចណាស់ ៣ម៉ោងនិង៣០នាទី។

-កំរិតប្រើដំបូង 20mg នៃជាតិដែក (1ml នៃសូលុយស្យុងថ្នាំនេះ) ត្រូវប្រើជាកំរិតធ្វើតេស្តពេលព្យួរសេរ៉ូម ក្នុងរយៈពេលលើសពី១៥នាទី។
ប្រសិនបើមិនមានប្រតិកម្មរំខានកើតឡើងក្នុងពេលធ្វើតេស្តនេះទេ កំរិតប្រើ ដែលនៅសល់ក្នុងសូលុយសេរ៉ូមត្រូវបន្តប្រើ ក្នុងអត្រាបង្ហូរមិនលើសពី 100mg នៃជាតិដែក ក្នុងរយៈពេល១៥នាទី។

**សំរាប់ប្រើចាក់តាមសរសៃឈាម៖**
-ត្រូវចាក់ថ្នាំនេះយឺតៗតាមសរសៃឈាមក្នុងអត្រា 1ml នៃសូលុយស្យុងថ្នាំ ក្នុងរយៈពេល១នាទី ហើយមិនត្រូវប្រើលើសពី 10ml នៃសូលុយស្យុងថ្នាំ (200mg នៃជាតិដែក) ពេលចាក់ម្តងទេ។
-មុនពេលប្រើ ចាក់យឺតៗតាមសរសៃឈាម កំរិតធ្វើតេស្ត 1ml នៃសូលុយស្យុងថ្នាំ (20mg នៃជាតិដែក) ត្រូវចាក់យឺតៗតាមសរសៃឈាមក្នុងរយៈពេលពី១ទៅ២នាទី។
ប្រសិនបើមិនមានប្រតិកម្មរំខានកើតឡើងក្នុងរយៈពេល១៥នាទីពេលធ្វើតេស្តនេះទេ ត្រូវបន្តប្រើសូលុយស្យុងថ្នាំដែលនៅសល់។
ក្រោយពេលចាក់ថ្នាំនេះរួច អ្នកជំងឺត្រូវបានណែនាំឲ្យលាដៃឲ្យត្រង់។

**សំរាប់ប្រើចាក់តាមឧបករណ៍លាងឈាម៖**
-សូលុយស្យុងថ្នាំនេះអាចប្រើចាក់បញ្ចូលទៅក្នុងសរសៃឈាមតាមរយៈឧបករណ៍លាងឈាមផ្ទាល់តែម្តងបានតាមកំរិតប្រើដូចក្នុងការចាក់តាមសរសៃឈាមដែរ។
-មុនពេលប្រើ ចាក់យឺតៗតាមសរសៃឈាម កំរិតធ្វើតេស្ត 1ml នៃសូលុយស្យុងថ្នាំ (20mg នៃជាតិដែក)ត្រូវចាក់យឺតៗតាមសរសៃឈាមក្នុងរយៈពេលពី១ទៅ២នាទី។
ប្រសិនបើមិនមានប្រតិកម្មរំខានកើតឡើងក្នុងរយៈពេល១៥នាទីពេលធ្វើតេស្តនេះទេ ត្រូវបន្តប្រើសូលុយស្យុងថ្នាំដែលនៅសល់។
ក្រោយពេលចាក់ថ្នាំនេះរួច អ្នកជំងឺត្រូវបានណែនាំឲ្យលាដៃឲ្យត្រង់។

**សំរាប់ប្រើចំពោះមនុស្សពេញវ័យដែលមានជំងឺខ្សោយតំរងនោមដែលទាក់ទងនឹងការលាងឈាមតាមសរសៃឈាម៖**
-ត្រូវចាក់ថ្នាំនេះយឺតៗតាមសរសៃឈាមក្នុងអត្រា 100mg នៃកំរិតជាតិដែកនៃសូលុយស្យុងថ្នាំ ក្នុងរយៈពេលពី២ទៅ៥នាទី ឬប្រើលាយជាមួយសូលុយសេរ៉ូមប្រៃក្នុងអត្រា 100mg នៃជាតិដែកនៃសូលុយស្យុងថ្នាំ ក្នុង100mlនៃសូលុយស្យុងសេរ៉ូមប្រៃ ០,៩% ដោយព្យួរតាមសរសៃឈាមក្នុងរយៈពេលយ៉ាងហោចណាស់១៥នាទី នៅរៀងរាល់ការលាងឈាមម្តងៗ។ឱសថនេះត្រូវប្រើអំឡុងពេលចាប់ផ្តើមដំណើរការណ៍លាងឈាម។
-កំរិតប្រើសរុបធម្មតានៃឱសថនេះគឺ 1000mg។ ឱសថនេះអាចប្រើម្តងទៀតបាន នៅពេលណាដែលមានការថយចុះកំរិតជាតិដែកក្នុងឈាមកើតឡើង។

**សំរាប់ប្រើចំពោះមនុស្សពេញវ័យដែលមានជំងឺខ្សោយតំរងនោមដែលមិនទាក់ទងនឹងការលាងឈាម៖**
-ត្រូវចាក់ថ្នាំនេះយឺតៗតាមសរសៃឈាមក្នុងអត្រា 200mg នៃកំរិតជាតិដែកនៃសូលុយស្យុងថ្នាំ ក្នុងរយៈពេលពី២ទៅ៥នាទី ឬប្រើលាយជាមួយសូលុយសេរ៉ូមប្រៃ ក្នុងអត្រា 200mg នៃជាតិដែកនៃសូលុយស្យុងថ្នាំក្នុង100ml នៃសូលុយស្យុងសេរ៉ូមប្រៃ ០,៩% ដោយព្យួរតាមសរសៃឈាមក្នុងរយៈពេលយ៉ាងហោចណាស់១៥នាទី។
មិនមានការសិក្សាបញ្ជាក់គ្រប់គ្រាន់ទៅលើកំរិតប្រើឱសថនេះនៅពេលប្រើលាយជាមួយសូលុយសេរ៉ូមប្រៃក្នុង អត្រា 500mg នៃជាតិដែកនៃសូលុយស្យុងថ្នាំ ទៅក្នុង 2500ml នៃសូលុយស្យុងសេរ៉ូមប្រៃ ០,៩% ដោយព្យួរតាមសរសៃឈាមក្នុងរយៈពេលពី ៣ម៉ោង៣០នាទីទៅ៤ម៉ោង ក្នុងថ្ងៃទី១និងថ្ងៃទី១៤។
ឱសថនេះអាចប្រើម្តងទៀតបាន នៅពេលណាដែលមានការថយចុះកំរិតជាតិដែកក្នុងឈាមកើតឡើង។

**សំរាប់ប្រើចំពោះមនុស្សពេញវ័យដែលមានជំងឺខ្សោយតំរងនោមដែលទាក់ទងនឹងការលាងឈាមតាមផ្ទៃខាងក្នុងនៃពោះ៖**
-កំរិតប្រើត្រូវចែកជា៣ដង ដោយបង្ហូរយឺតៗតាមសេរ៉ូម ក្នុងរយៈពេល២៨ថ្ងៃ ដោយបែងចែកកំរិតប្រើដូចខាងក្រោម៖

- ពេលព្យួរ២ដងដំបូង ក្នុងកំរិត 300mg នៃកំរិតជាតិដែក ក្នុងរយៈពេល ១ម៉ោង៣០នាទី។
- ១៤ថ្ងៃក្រោយមក ត្រូវព្យួរ១ដងទៀត ក្នុងកំរិត 400mg នៃកំរិតជាតិដែក ក្នុងរយៈពេល ២ម៉ោង៣០នាទី។ឱសថនេះត្រូវលាយជាមួយកំរិតអតិបរិមា 250ml នៃសូលុយស្យុងសេរ៉ូមប្រៃ ០,៩%។
- ឱសថនេះអាចប្រើម្តងទៀតបាន នៅពេលណាដែលមានការថយចុះកំរិតជាតិដែកក្នុងឈាមកើតឡើង។

**សំរាប់ប្រើព្យាបាលបន្តចំពោះកូនក្មេង(អាយុចាប់ពី២ឆ្នាំឡើងទៅ) ដែលមានជំងឺខ្សោយតំរងនោមរ៉ាំរ៉ៃ និងលាងឈាមតាមសរសៃឈាម៖**
-មិនមានការសិក្សាបញ្ជាក់ពីកំរិតប្រើឱសថនេះចំពោះកូនក្មេងដែលមានស្ថានភាពជំងឺខាងលើនេះទេ។
-សំរាប់ការព្យាបាលបំរុងជាតិដែក៖ កំរិតប្រើគឺ 0.5mg ក្នុងទម្ងន់១គីឡូក្រាម (មិនត្រូវប្រើលើសពី 100mg ក្នុងពេលប្រើម្តងទេ)
រៀងរាល់២សប្តាហ៍ម្តង សំរាប់រយៈពេល១២សប្តាហ៍ ដោយចាក់យឺតៗតាមសរសៃឈាមក្នុងរយៈពេល៥នាទី ឬលាយក្នុង 25ml នៃសូលុយស្យុងសេរ៉ូមប្រៃ ០,៩% ហើយព្យួរក្នុងរយៈពេលពី៥ទៅ៦០នាទី។ ឱសថនេះអាចប្រើម្តងទៀតបាន ប្រសិនបើចាំបាច់។

**សំរាប់ប្រើព្យាបាលបន្តចំពោះកូនក្មេង(អាយុចាប់ពី២ឆ្នាំឡើងទៅ) ដែលមានជំងឺខ្សោយតំរងនោមរ៉ាំរ៉ៃមិនទាក់ទង នឹងការលាងឈាម ៖**
-មិនមានការសិក្សាបញ្ជាក់ពីកំរិតប្រើឱសថនេះចំពោះកូនក្មេងដែលមានស្ថានភាពជំងឺខាងលើនេះទេ។
-សំរាប់ការព្យាបាលបំរុងជាតិដែក៖ កំរិតប្រើគឺ 0.5mg ក្នុងទម្ងន់១គីឡូក្រាម (មិនត្រូវប្រើលើសពី 100mg ក្នុងពេលប្រើម្តងទេ)
រៀងរាល់៤សប្តាហ៍ម្តង សំរាប់រយៈពេល១២សប្តាហ៍ ដោយចាក់យឺតៗតាមសរសៃឈាមក្នុងរយៈពេល៥នាទី ឬលាយក្នុង 25ml នៃសូលុយស្យុងសេរ៉ូមប្រៃ ០,៩% ហើយព្យួរក្នុងរយៈពេលពី៥ទៅ៦០នាទី។ ឱសថនេះអាចប្រើម្តងទៀតបាន ប្រសិនបើចាំបាច់។

X **លេខបញ្ជិកា** : CAM N0748IP-16

XI **ផលិតដោយ** : Nitin Lifesciences Ltd., (India)
បានបកប្រែនិងត្រួតពិនិត្យដោយនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង។
លេខ:១៧៤១/១៧ឱអបស ចុះថ្ងៃទី០៥ ខែ មិថុនា ឆ្នាំ២០១៧